# យើងដើរតាមព្រះយេស៊ូវ គ្រីស្ទ

*អែលឌើរ ខ្វីនធីន អិល យុក*
*ជាក្រុមនៃពួកសាវកដប់ពីរនាក់*

ខ្ញុំសូមសម្តែងការអបអរចំពោះ ស៊ិស្ទើ ឡាន់ និងទីប្រឹក្សារបស់គាត់ចំពោះការបំរើដ៏អស្ចារ្យ ដែលពួកគេផ្តល់ឱ្យ។

វាគឺជាការទទួលខុសត្រូវមួយយ៉ាងពិសេសក្នុងការនិយាយនៅក្នុងថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរ ទៅកាន់ពួកបរិសុទ្ធ ថ្ងៃចុងក្រោយទាំងអស់នៅជុំវិញពិភពលោក ដែលជាអ្នកស្រឡាញ់ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវ គ្រីស្ទ។ យើងប្រារព្ធនាព្រឹកនេះនូវការយកឈ្នះលើសេចក្តីស្លាប់របស់ទ្រង់។ យើងរីករាយចំពោះ ការយល់ដឹងរបស់យើង និងមានអំណរដ៏ស្មោះអស់ពីដួងចិត្ត ចំពោះឆន្ទៈធ្វើពលិកម្មដង្វាយធួន របស់ព្រះអង្គសង្គ្រោះ ជំនួសយើង។ ការដែលទ្រង់សុខចិត្តធ្វើតាមឆន្ទៈព្រះវរបិតាទ្រង់ មានជ័យជំនះយ៉ាងឧត្តម លើសេចក្តីស្លាប់ និងជាព្រឹត្តិការណ៍ដ៏អស្ចារ្យនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ ខ្ញុំមានអំណរគុណ ចំពោះឱកាសដែលបាននិយាយអំពីការធ្វើតាមព្រះអង្គសង្គ្រោះ។

នៅគ្រាចុងក្រោយពីរថ្ងៃ ក្នុងជីវិតនៃការបំរើរបស់ព្រះអង្គសង្គ្រោះមុនការឆ្កាងរបស់ទ្រង់ គឺមានសារៈសំខាន់យ៉ាង ជ្រាលជ្រៅ វាគឺជារឿងមួយហួសពីការយល់ដឹងរបស់យើង។ អ្វីដែលសំខាន់ចំពោះជោគវាសនាដ៏អស់កល្បរបស់យើងគឺកើតឡើងនៅថ្ងៃព្រហស្បត៍ និងថ្ងៃសុក្រ គឺជាថ្ងៃដែលព្រះគ្រីស្ទត្រូវគេឆ្កាង។ អាហារចុងក្រោយ គឺអាហារ ថ្ងៃបុណ្យរំលង «...ដែលបានបង្កើតជាថ្ងៃបុណ្យរំឭក ពីការរំដោះប្រជាជនអ៊ីស្រាអែលចេញពីទាសភាព» 1 បានចាប់ផ្តើមនៅយប់ថ្ងៃ ព្រហស្បត៍។ ពិធីការ និងគោលលទ្ធិប្រកបដោយសារៈសំខាន់ដ៏អស្ចារ្យ គឺបានចាប់ផ្តើមបញ្ចូលនៅអាហារចុងក្រោយ។ ខ្ញុំនឹងលើកឡើងបីចំណុចប៉ុណ្ណោះ។ ទីមួយគឺព្រះអង្គសង្គ្រោះណែនាំពិធីសាក្រាម៉ង់។ ទ្រង់បានយកនំប៉័ង ហើយកាច់ជាដុំ និងអធិស្ឋាន ព្រមទាំងបានហុចឱ្យសិស្សរបស់ទ្រង់ ហើយមានព្រះបន្ទូលថា៖ «នេះហើយជារូបកាយខ្ញុំ ដែលបានប្រទាន មកសំរាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះដើម្បីរំឭកពីខ្ញុំចុះ»។ 2 នេះគឺជារបៀបដែលទ្រង់ស្ថាបនាពីធីសាក្រាម៉ង់ឡើង។ ទីពីរ ការសង្កត់ធ្ងន់ខ្លាំងរបស់ទ្រង់ គឺបង្រៀនអំពីគោលលទ្ធិនៃសេចក្តីស្រឡាញ់គឺជាគោលការណ៍ដ៏ចម្បងជាងគេ។ ទ្រង់បានបង្រៀនថា៖ «គេនឹងដឹងថាអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំដោយសារសេចក្តីនេះឯង គឺដោយសារអ្នករាល់គ្នាមាន សេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក»។ 3 ទីបីតាមរយៈការអង្វរជំនួស ឬការណែនាំរបស់ព្រះគ្រីស្ទ «ព្រះវិញ្ញាណបរិសុទ្ធបានសន្យាដល់សាវក» 4 ជាគូអង្គលួងលោមចិត្តមួយផ្សេងទៀត។

ក្រោយមក ព្រះអង្គសង្គ្រោះបានសម្រេចនូវដង្វាយធួន។ ទ្រង់លើកដាក់មកលើ ខ្លួនទ្រង់នូវ «នឹមនៃអំពើបាបរបស់មនុស្សលោក» និង «សេចក្តីស្អប់ខ្ពើមដែលសាតាំង...អាចធ្វើឱ្យរបួស»។5

នៅដំណើរការនេះ ទ្រង់បានស៊ូទ្រាំការសាកល្បងប្រឌិតក្លែងបន្លំ និងព្រឹត្តការណ៍ដ៏អាក្រក់ និងអន្តរាយ ដែលនាំឱ្យមានការឆ្កាងទ្រង់។ ការណ៍នេះ ត្រូវបានបញ្ចប់នៅក្នុងការរស់ឡើងវិញដោយជោគជ័យរបស់ព្រះគ្រីស្ទ នៅថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរ។ ព្រះគ្រីស្ទ បានបំពេញបេសកកម្ម ដ៏ពិសិដ្ឋរបស់ទ្រង់ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះ។ យើងនឹងរស់ឡើងវិញពីសេចក្ដីស្លាប់ ហើយវិញ្ញាណរបស់យើងនឹងផ្គុំជាមួយរូបកាយរបស់យើង។ ផ្អែកលើភាពសក្តិសមផ្ទាល់ តាមរយៈព្រះគុណរបស់ទ្រង់ យើងមានឱកាសដ៏ស្រស់បំព្រង នៃការត្រឡប់ទៅកាន់វត្តមានរបស់ព្រះវិញ។ 6

ព្យាការីយ៉ូសែប ស្ម៊ីធ មានប្រសាសន៍ អំពីព្រឹត្តិការណ៍បុណ្យអ៊ីស្ទើរ ថា៖ «គោលការណ៍គ្រឹះនៃសាសនារបស់យើង គឺទីបន្ទាល់អំពីសាវក និងព្យាការី ចំពោះព្រះយេស៊ូវ គ្រីស្ទថាទ្រង់បានសុគត់ បានបញ្ចុះ និងមានព្រះជន្មរស់ជាថ្មីនៅថ្ងៃទីបី ហើយទ្រង់បានឡើងទៅស្ថានសួគ៌ ហើយអ្វីផ្សេងទៀតដែលទាក់ទងនឹងសាសនារបស់យើង គ្រាន់តែជារឿងបន្ទាប់បន្សំចំពោះការណ៍នេះប៉ុណ្ណោះ»។ 7

ខណៈពេលដែលយើងត្រេកអរចំពោះអត្ថន័យដ៏វិសេសវិសាលនៃសួនច្បារគែតសេម៉ានី និងភ្នំរលាក្បាល នោះការផ្ដោត សំខាន់របស់យើងគឺតែងតែទៅលើការរស់ឡើងវិញរបស់ព្រះអម្ចាស់។ ហ្វ្រេឌឺរីក ហ្វារ៉ា គឺជាទេវវិទូអង់គ្លេស និងជាអ្នកជឿម្នាក់ បានថ្លែងទីបន្ទាល់ថា អ្នកមានជំនឿកាលពីជំនាន់មុន នៅក្នុងព្រះវិហារគ្រីស្ទានដំបូងគេ បានចាត់ ទុកព្រះអង្គសង្គ្រោះជា «...ព្រះគ្រីស្ទដែលរស់ឡើងវិញ អស់កល្បជានិច្ច និងរុងរឿង» ហើយ «មិនបានគិតថាទ្រង់ នៅលើឈើឆ្កាងនោះទេ ប៉ុន្តែទ្រង់គង់នៅលើបល្ល័ង្ក...»។ 8

ប្រធាន ហ៊ិងគ្លី បានបង្រៀនថា សារលិខិតរបស់យើងទៅកាន់ពិភពលោកគឺថាទ្រង់មានព្រះជន្មរស់! និមិត្តរូបនៃ ព្រះគ្រីស្ទ ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយនឹងរកឃើញដោយការបង្ហាញយ៉ាង មានអត្ថន័យបំផុត នូវសេចក្ដីជំនឿ របស់យើង និងរបៀបដែលយើងរស់នៅតាមដំណឹងល្អរបស់ទ្រង់។ 9

នៅពេលយើងសញ្ជឹងគិតតើវាមានអត្ថន័យដូចម្តេចក្នុងការធ្វើជាពួកគ្រីស្ទាននាបច្ចុប្បន្ននេះ ចូរគិតអំពីតើផ្លូវនៃ ការធ្វើជាសិស្សនឹងទាមទារអ្វីខ្លះពីយើង។ ខ្ញុំសូមផ្ដល់យោបល់ថាយើងត្រូវសញ្ជឹងគិត ហើយធ្វើតាមគំរូដ៏ត្រឹមត្រូវ តាមអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ នៅពីរថ្ងៃចុងក្រោយនៃជីវិតខាងសាច់ឈាមរបស់ទ្រង់។

ទីមួយ ចូរពិចារណាពី ការណែនាំពិធីសាក្រាម៉ង់របស់ព្រះអង្គសង្គ្រោះ។ ព្រះអង្គសង្គ្រោះជ្រាបអំពីអ្វី ដែលនឹងកើតឡើង ចំពោះទ្រង់។ បេសកកម្មដង្វាយធួនដ៏ពិសិដ្ឋរបស់ទ្រង់បានចាប់ផ្ដើមជាមួយនឹងសង្គ្រាមនៅស្ថានសួគ៌ នៅក្នុងជីវិតមុន ជីវិតនេះ គឺបានលាតត្រដាងនៅល្ងាចនោះ និងនៅថ្ងៃបន្ទាប់។  នៅពេលការវិនិច្ឆ័យ រៀបនឹងធ្វើឡើងពីសំណាក់បច្ចាមិត្ត របស់ទ្រង់ គឺគ្មានភស្តុងតាងណាបន្តិចដែលបង្ហាញថាទ្រង់បានរៀបចំការពារប្រឆាំងនឹងការចោទប្រកាន់ មិនពិតនោះ ឡើយ។ ផ្ទុយទៅវិញព្រះអង្គសង្គ្រោះ បានណែនាំពិធីការពិសិដ្ឋនៃពិធីសាក្រាម៉ង់ដល់សិស្សរបស់ទ្រង់។ នៅពេលខ្ញុំសញ្ជឹងគិតអំពីស្ថានភាពដ៏

ឱឡារិកនោះ អារម្មណ៍របស់ខ្ញុំ ទទួលបានការប៉ះទង្គិចយ៉ាងខ្លាំង។ ការប្រជុំសាក្រាម៉ង់ គឺជាការប្រជុំដ៏ពិសិដ្ឋ និងបរិសុទ្ធបំផុត លើសអស់ទាំងការប្រជុំនៅក្នុងសាសនាចក្រ។ បន្ទាប់ពី ការរស់ឡើងវិញរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានបង្កើតពិធីសាក្រាម៉ង់ក្នុងចំណោមសាសន៍នីហ្វៃ។ 10 បើយើងចង់ធ្វើជាសិស្សរបស់ទ្រង់ ហើយចង់ធ្វើជាសមាជិកដែលប្ដេជ្ញាចិត្តចំពោះសាសនាចក្ររបស់ទ្រង់ យើងត្រូវតែចងចាំ និងមានគារវភាព ចំពោះ ពិធីសាក្រាម៉ង់។ វាអនុញ្ញាតឱ្យយើងម្នាក់ៗបង្ហាញពីចិត្តសង្រេង និងវិញ្ញាណទន់ទាបរបស់យើង ដែលមានឆន្ទៈ ធ្វើតាម ព្រះអង្គសង្គ្រោះ ចង់ប្រែចិត្ត ហើយក្លាយជាពួកបរិសុទ្ធតាមរយៈ ដង្វាយធួនរបស់ព្រះគ្រីស្ទ។ 11 ពិធីសាក្រាម៉ង់ អនុញ្ញាតឱ្យយើងធ្វើជាសាក្សីចំពោះព្រះថា យើងនឹងចងចាំព្រះរាជបុត្រារបស់ទ្រង់ និងគោរពតាមបទបញ្ញត្តិរបស់ទ្រង់ នៅពេលយើងរំឭកឡើងវិញពីសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក។ 12 ការណ៍នេះបង្កើនសេចក្ដីស្រឡាញ់ និងការអរគុណរបស់យើងចំពោះព្រះវរបិតា និងព្រះរាជបុត្រា។

ព្រះអង្គសង្គ្រោះក៏បានគូសបញ្ជាក់អំពីសេចក្ដីស្រឡាញ់ និងសាមគ្គីភាព ហើយទ្រង់បានប្រកាសថា យើងនឹងត្រូវបានគេ ស្គាល់ថា ជាសិស្សរបស់ទ្រង់ បើយើងស្រឡាញ់គ្នាទៅវិញទៅមក។ នៅពេលយើងសញ្ជឹងគិតអំពីដង្វាយធួន ដែល មានលក្ខណៈអស់កល្បជានិច្ច បទបញ្ញត្តិដូច្នេះគឺតម្រូវឱ្យយើងប្រឹងប្រែង។ យើងបង្ហាញសេចក្ដីស្រឡាញ់របស់យើង ចំពោះព្រះ នៅពេលយើងគោរពតាមបទបញ្ញត្តិរបស់ទ្រង់ និងបំរើកូនចៅទ្រង់។ យើងយល់មិនអស់អំពីដង្វាយធួនទេ ប៉ុន្តែយើងអាចចំណាយពេលព្យាយាមរស់នៅឱ្យកាន់តែមានសេចក្ដី ស្រឡាញ់ និងមានចិត្តសប្បុរស មិនថាត្រូវប្រឈមមុខនឹងបច្ចាមិត្តរបៀបណានោះទេ។

ព្រះអង្គសង្គ្រោះដាក់ឱ្យពួកសិស្សរបស់ទ្រង់ស្រឡាញ់គ្នាទៅវិញទៅមក ហើយរបៀបដ៏អស្ចារ្យ និងប្រកបដោយអំណាច ដែលទ្រង់បានបង្រៀនគោលការណ៍នេះ នៅយប់ចុងក្រោយ គឺជាព្រឹត្តការដ៏សំខាន់ និងអស្ចារ្យបំផុត មកពីថ្ងៃចុងក្រោយ នៃជីវិតរមែងស្លាប់របស់ទ្រង់។ ទ្រង់មិនមែនបង្រៀនថ្នាក់សាមញ្ញមួយអំពីឥរិយាបទមានក្រមសីលធម៌នោះទេ។ នេះគឺជាព្រះរាជបុត្រារបស់ព្រះ ដែលកំពុងតែអង្វរដល់ពួកសាវករបស់ទ្រង់ និងពួកសិស្សទាំងអស់ ដែលនឹងដើរតាមពួកគេ ឱ្យចងចាំ និងធ្វើតាម ការបង្រៀនដ៏សំខាន់បំផុតរបស់ទ្រង់នេះ។ របៀបដែលយើងទំនាក់ទំនង និងប្រាស្រ័យទាក់ទងនឹងគ្នា គឺជារង្វាស់នៃឆន្ទៈរបស់យើង ដើម្បីធ្វើតាមព្រះយេស៊ូវ គ្រីស្ទ។

នៅពេលយើងស្ដាប់សារលិខិតនៃសន្និសីទនេះ យើងនឹងទទួលការប៉ះនឹងដួងចិត្តរបស់យើង ហើយធ្វើការដោះស្រាយ និងការតាំងចិត្តដើម្បីធ្វើឱ្យបានកាន់តែល្អប្រសើរ។ ប៉ុន្តែនៅព្រឹកថ្ងៃច័ន្ទ យើងនឹងត្រឡប់ទៅធ្វើការ ទៅសាលារៀន និងទៅតំបន់រស់នៅ ហើយទៅកាន់ពិភពលោកមួយ ដែលមានករណីជាច្រើនស្ថិតនៅក្នុងចលាចល។ មានមនុស្សជាច្រើន នៅក្នុងពិពភលោកនេះ កំពុងភ័យខ្លាច និងខឹងជាមួយគ្នាទៅវិញទៅមក។ ទោះបីយើងយល់អំពីអារម្មណ៍ទាំង នេះ ក៏យើងចាំបាច់និយាយស្ដីដោយគួរសម ហើយគោរពនៅក្នុងការប្រាស្រ័យទាក់ទងរបស់យើង។ នេះគឺជា ការពិតពិសេស នៅពេលយើងមិនយល់ស្រប។

ព្រះអង្គសង្គ្រោះបានបង្រៀនយើងថា ឱ្យស្រឡាញ់ទាំងខ្មាំងសត្រូវរបស់ យើងផង។ 13 យើងរាល់គ្នាក្នុង
ចំនួនដ៏ច្រើនបានស្តាប់ឮដំបូន្មាននេះ។ ប៉ុន្តែនៅមានមនុស្សមួយចំនួន ដែលមានអារម្មណ៍ ថា ការបញ្ចេញ
កំហឹងផ្ទាល់ខ្លួន ឬការកាន់គំនិតយ៉ាងខ្លាំងរបស់ពួកគេ គឺមានសារៈសំខាន់ជាង ការប្រព្រឹត្តឲ្យបានដូចដែល
ព្រះយេស៊ូវគ្រីស្ទបានរស់នៅ និងបានបង្រៀន។ ខ្ញុំសូមអញ្ជើញយើងម្នាក់ៗ ជាបុគ្គល ឱ្យទទួលស្គាល់ថា
របៀបដែលយើងមិនយល់ស្រប គឺជារង្វាស់ពិតមួយ នៃខ្លួនយើងជានរណា ហើយថាតើយើងជាអ្នកដើរ
តាមពិតរបស់ព្រះអង្គសង្គ្រោះ ឬក៏អត់។  វាសមរម្យដើម្បីមិនយល់ស្រប ប៉ុន្តែវា មិនសមរម្យ ដែលយើង
គំរោះគំរើយ នោះទេ។ អំពើហឹង្សា និង ការបំផ្លាញទ្រព្យសារធារណៈ គឺមិនមែនជាចម្លើយចំពោះការមិន
យល់ស្របរបស់យើងទេ។ បើសិនជាយើងបង្ហាញសេចក្តីស្រឡាញ់ និងគោរពទៅដល់ទាំងសត្រូវរបស់
យើង នោះយើងនឹងកាន់តែប្រែក្លាយដូចជាព្រះគ្រីស្ទ។

សេចក្តីសន្យារបស់ព្រះអង្គសង្គ្រោះ ដើម្បីប្រទានព្រះវិញ្ញាណបរិសុទ្ធ ដល់ពួកសាវកទាំងដប់ពីរនាក់ គឺ
សារៈសំខាន់បំផុត នៅក្នុងការទទួលស្គាល់តួនាទីដ៏មហិមានៃព្រះវិញ្ញាណបរិសុទ្ធ ជាសមាជិកនៃក្រុមព្រះ
ទាំងបី។ ព្រះវិញ្ញាណបរិសុទ្ធ ជាតួអង្គវិញ្ញាណមួយ ជាអង្គលួងលោមចិត្ត ដែលថ្លែងជាសាក្សីចំពោះព្រះ
វរបិតា និងព្រះរាជបុត្រា ព្រមទាំងបើកសម្តែង ការពិតគ្រប់យ៉ាង ហើយទ្រង់ស្អាងអស់អ្នកដែលប្រែចិត្ត
ហើយបានទទួលពិធីបុណ្យជ្រមុជទឹក។ ទ្រង់ត្រូវបានសំដៅថា ជាព្រះវិញ្ញាណ បរិសុទ្ធនៃសេចក្តីសន្យា
ហើយបញ្ជាក់ថាទទួលយកចំពោះព្រះនូវទង្វើរសុចរិត ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយរបស់
យើងម្នាក់ៗ។ 14 ពួកគេដែលត្រូវបានផ្សាភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃ សេចក្តីសន្យា នោះទទួល
នូវអ្វីៗទាំងអស់ ដែលព្រះវរបិតាមាន។ 15

យើងរស់នៅក្នុងពិភពលោកអ៊ូអែរ ប្រកបដោយការឈ្លោះប្រកែក នៅគ្រប់ទីកន្លែងដែលអាចបើកមើល ឬ
ស្តាប់ព័ត៌មាន តន្ត្រី ឬរឿងដែលមិនសមហេតុផលនៅស្ទើរតែគ្រប់ពេល។ បើសិនជាយើងចង់មានការ
បំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ យើងត្រូវតែរកពេល ដើម្បីបង្អង់ល្បឿន ពិចារណា អធិស្ឋាន និងរស់នៅ
ដើម្បីយើងមានភាពសក្តិសម ដើម្បីទទួល និងធ្វើសកម្មភាព តាមការបំផុសគំនិតរបស់ទ្រង់។ វាគឺជាឯក
សិទ្ធរបស់យើងក្នុងនាមជាសមាជិកដើម្បីទទួលពន្លឺ និងចំណេះដឹងមកពីទ្រង់ រហូតដល់ថ្ងៃល្អឥតខ្ចោះ។16
ការសាកល្បងនៃជង្ហាយធ្ងន់ដែលព្រះអង្គសង្គ្រោះប្រឈមមុខនៅក្នុងសួនច្បារគែតសេម៉ានី និងនៅលើឈើ
ឆ្កាង គឺជាគំរូមួយដ៏អស្ចារ្យសំរាប់យើង។ ទ្រង់ប្រឈមមុខនឹងការឈឺចាប់ខាងសតិអារម្មណ៍ សាច់ឈាម
និងខាងវិញ្ញាណ ដែលហួសពីការយល់ដឹងរបស់យើង។ នៅក្នុងសួនច្បារគែតសេម៉ានីទ្រង់ បានអធិស្ឋានទៅ
ព្រះវរបិតាទ្រង់ថា «ឱព្រះវរបិតានៃទូលបង្គំ អើយ បើសិនជាបាននោះសូមឱ្យពែងនេះកន្លងហួសពីទូលបង្គំ
ទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែ ព្រះហឫទ័យទ្រង់វិញ»។ 17 ក្នុងនាមជាសិស្សរបស់ទ្រង់
នឹងមានពេលដែល យើង នឹងនឿយហត់ ហើយ ត្រូវគេធ្វើទុក្ខបុកម្នេញទាំង អយុត្តិធម៌ និង ការសើចចំអក
មិនត្រឹមត្រូវ ហើយត្រូវប្រឈមមុខនឹងខ្យល់ព្យុះខាងលោកិយ៍ និងខាងវិញ្ញាណ ដែលមានទំហំហាក់បីដូចជា
មិនអាចអត់ទ្រាំបាន  ចំពោះយើង ហើយជួបនឹងពែងល្វីង ដែលយើងបានអធិស្ឋាន ថាសូមកន្លងហួសពី

យើងទៅ។ គ្មាននរណាម្នាក់ ត្រូវបានលើកលែងពីព្យុះភ្លៀងជីវិតទេ។

យើង កំពុងរៀបចំខ្លួនសំរាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ។ ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ណាស់ថា គ្មាននរណាម្នាក់ដឹងថានឹងកើតឡើងពេលណានោះទេ។ ព្រះគម្ពីរគ្រាន់តែប្រាប់យើងថានៅថ្ងៃចុងក្រោយ នឹងមានរឿង ល្វឹងល្វើយចត់ជាច្រើនកើតឡើង នឹងមាន៖ «...កក្រើកដីនៅកន្លែងផ្សេង»18 និង «...រលកទឹកសមុទ្របោកបក់ហួសណា ហួសណី»។ 19

ការបំផ្លិចបំផ្លាញដោយសាររញ្ជួយផែនដី និងរលកស៊ូណាមិទើបតែកើតឡើងក្នុងពេលថ្មីៗនេះ នៅកន្លែងផ្សេងៗជាច្រើន រួមទាំង ឈីលី ហៃទី និងកោះជាច្រើននៅមហាសមុទ្រប៉ាស៊ីហ្វិក។ ពីរបីសប្តាហ៍កន្លងទៅហើយ ប៊ីស្សពអធិបតី អេច ដេវីឌ បើរតុន អែលឌើរ ថាត អរ ខាលីស្ទើរ និងខ្ញុំបានជួបជាមួយពួកបរិសុទ្ធដែលបានបាត់បង់សមាជិកគ្រួសារ ដោយសាររលកស៊ូណាមិ ដែលបានបោកប៉ះភាគ ខាងកើតនៃកោះសាម័រកាលពីខែ កញ្ញា កន្លងទៅនេះ។ សាលាប្រជុំទាំងមូលពេញ ហើយជាការប្រជុំដ៏រំជួលចិត្តមួយ។ យើងបានអះអាងដល់សមាជិកជំរើសទាំងនេះថា ពីព្រោះដង្វាយធួនរបស់ព្រះយេស៊ូវ គ្រីស្ទ នោះពួកគេបានជួបជុំជាមួយ មនុស្សជាទីស្រឡាញ់ដែលពួកគេបាត់បង់នោះម្តងទៀត។

ប្រធានស្តេក សូនី ភីសេល កំពុងតែបើកឡាននៅពេលដែលគាត់បានឃើញរលកដ៏ធំនោះបក់បោកមកយ៉ាងឆ្ងាយ ពីសមុទ្រ។ គាត់បានចុចស៊ីផ្លេឡាន ហើយបញ្ឈប់កុមារដែលកំពុងដើរតាមផ្លូវទៅសាលារៀន ហើយព្រមានពួកគេឱ្យរត់ទៅទីខ្ពស់ ហើយមានសុវត្ថិភាពឱ្យលឿនបំផុតតាមដែលអាចធ្វើទៅបាន។ កុមារទាំងនោះបានធ្វើតាមការណែនាំ របស់គាត់។ គាត់បានបើកឡានជាមួយកូនស្រីអាយុ 4 ឆ្នាំរបស់គាត់ ហើយព្យាយាមទៅទទួលម្តាយ របស់គាត់។ មុនពេលគាត់ទៅជួបម្តាយគាត់ នីវ៉ូទឹកបានជន់លេចឡាន របស់គាត់ ហើយកើនឡើងជាង 90 ម៉ែត្រ ដែលធ្វើឱ្យឡានគាត់ កៀងជាប់នឹងដើមឈើមួយ។ គាត់បានយកកូនស្រីគាត់ដាក់លើដំបូលឡានជាកន្លែង ដែលមាន សុវត្ថិភាពយ៉ាងប្រញាប់ ហើយហែលទឹកទៅសង្គ្រោះម្តាយរបស់គាត់ ដែលបានឡើងទៅលើមែកឈើមួយផ្សេងទៀត នៅជិតផ្ទះរបស់ពួកគេ។ គាត់ខំប្រឹងហែលទឹកជាមួយម្តាយរបស់គាត់ទៅកាន់ឡាន ដោយសុវត្ថិភាព។ មានមនុស្សជា ច្រើនដែលគ្មានសំណាងល្អ។ ពួកគេគ្មានពេលគ្រប់គ្រាន់ដើម្បីទៅកាន់ទីខ្ពស់ ហើយមានសុវត្ថិភាព។ មនុស្សជាច្រើន បានបាត់បង់ជីវិត ជាពិសេសគឺកូនក្មេង និងមនុស្សចាស់។

យើងបាននិយាយប្រាប់ក្រុមគ្រួសារសាម័រទាំងនោះថា សមាជិកនៅជុំវិញពិភពលោកទាំងមូល សូមបង្ហាញនូវសេចក្តី ស្រឡាញ់ និងការយកចិត្តទុកដាក់ ហើយបានអធិស្ឋានសំរាប់ពួកគេ ហើយបានធ្វើការបរិច្ចាគតាមរយៈដង្វាយតមអាហារ និងផ្តល់ជំនួយសប្បុរសធម៌ សំរាប់ទាំងអ្នកជាសមាជិក និងអ្នកជិតខាងរបស់គេ។ រឿងពិតដូចគ្នានេះក៏បានកើតឡើង ចំពោះសមាជិក និងអ្នកជិតខាតរបស់ពួកគេនៅ ឈីលី និងហៃទី។ យើងធ្វើដូច្នេះពីព្រោះយើងធ្វើតាមព្រះយេស៊ូវ គ្រីស្ទ។

ខណៈពេលដែលយើងជួបជុំជាមួយក្រុមគ្រួសារនៅសាម័រ សារៈសំខាន់ខាងវិញ្ញាណនៃការទៅទីខ្ពស់ និងការរស់នៅក្នុងជីវិតដ៏ប្រសើរ ហើយការប្រកាន់ខ្ជាប់នូវពិធីការនៃសេចក្តីសង្គ្រោះ គឺមានភាពច្បាស់លាស់បំផុត។ គំរូ និង ជីវិតរបស់ព្រះអង្គសង្គ្រោះបានបង្រៀនយើងនូវគំនិតខាងវិញ្ញាណឱ្យចៀសវាងពីផ្លូវទាប គឺការណ៍ទាំងឡាយដែល លោកិយនេះ ត្រួតត្រា។ ពេលខ្ញុំចាប់ដៃជាមួយសមាជិកទាំងឡាយបន្ទាប់ពីការប្រជុំរួចមក បងស្រីម្នាក់បានប្រាប់ខ្ញុំថា ក្រុមគ្រួសាររបស់នាងមិនទាន់បានទៅព្រះវិហារបរិសុទ្ធទេ ហើយពួកគេបានបាត់បង់កូនស្រីម្នាក់។ នាងនិយាយទាំង ទឹកភ្នែកថា ឥឡូវនេះគោលដៅរបស់ពួកគេគឺរៀបចំខ្លួនសំរាប់ពិធីការពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ ដើម្បីពួកគេអាច រស់នៅជួបជុំគ្នាដ៏អស់កល្បជានិច្ច។

នៅពេលខ្ញុំពិចារណាចំពោះអ្វីដែលបងស្រីនោះបាននិយាយ និងស្ថានភាពដែលបានកើតឡើងថ្មីៗនេះក្នុងពិភពលោក ខ្ញុំមានអារម្មណ៍ថាវាគឺជាការបន្ទាន់មួយក្នុងការប្រឹក្សាទៅកាន់អ្នកឱ្យស្វែងរកទីខ្ពស់ ទីជំរក និងការការពារដ៏ អស់កល្បជានិច្ចនៃព្រះវិហារបរិសុទ្ធ។

នៅក្នុងថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរ ថ្ងៃទី 3 ខែ មេសា 1836 មួយសប្តាហ៍បន្ទាប់ពីពិធីឧទ្ទិសព្រះវិហារបរិសុទ្ធខឺតឡង់ ពួកសាវកទាំងដប់ពីរនាក់បានធ្វើពិធីចែកចាយសាក្រាម៉ង់ ដែលជាអាហារចុងក្រោយរបស់ព្រះអម្ចាស់ដល់សមាជិក។ បន្ទាប់ពីការប្រជុំមាននូវការអធិស្ឋានដ៏ឧឡារិក និងស្ងៀមស្ងាត់។ ព្រះអង្គសង្គ្រោះបានបង្ហាញអង្គខ្លួនដល់ដោយក្តីរុងរឿង ចំពោះព្យាការី យ៉ូសែប និង អូលីវើរ ខៅឌើរី ហើយតាមរយៈព្យាការី ម៉ូសេ អេលីយ៉ា និងអេលីហ្សា លោកបានបើកទ្វារសំរាប់ការស្តារឡើងវិញនៃកូនសោរបព្វជិតភាពបន្ថែម រួមទាំងអំណាចផ្សារភ្ជាប់ដ៏ពិសិដ្ឋ ដែលរួបរួមក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ច។ 20

ថ្ងៃនេះនៅព្រឹកបុណ្យអ៊ីស្ទើរ នេះយើងរីករាយជាមួយនឹងអ្វីគ្រប់យ៉ាងដែលព្រះអង្គសង្គ្រោះបានធ្វើសំរាប់យើង។ ទ្រង់ធ្វើឱ្យយើងម្នាក់ៗអាចទទួលបាននូវសេចក្តីសង្គ្រោះ និងការលើកដំកើង។ ប៉ុន្តែយើងទាំងអស់គ្នាដូចជាកូនក្មេងកោះសាម័រ ដែរ យើងត្រូវតែរត់ឱ្យលឿនទៅទីខ្ពស់តាមដែលអាចធ្វើទៅបាន នៅទីនោះទ្រង់ផ្តល់ឱ្យយើងនូវសុវត្ថិភាព និងភាពសុខសាន្ត។

មធ្យោបាយមួយដែលយើងអាចធ្វើការណ៍នេះបានគឺតាមរយៈការកាន់តាមការបង្រៀនរបស់ព្យាការីដែលនៅរស់របស់យើងគឺ ប្រធាន ថូម៉ាស អេស ម៉នសុន ។ គាត់គឺជាគំរូមួយយ៉ាងល្អ ក្នុងការធ្វើតាមព្រះអង្គសង្គ្រោះ។

នៅក្នុងព្រឹកថ្ងៃបុណ្យអ៊ីស្ទើរដ៏ត្រចះត្រចង់នេះខ្ញុំបានគិតអំពីពាក្យពេចន៍ និពន្ធដោយ អេលីហ្សា អ័រ ស្នូ ដែលជាអ្នកបំរើដ៏ស្មោះត្រង់ម្នាក់ នៅក្នុងការស្តារឡើងវិញ។

«ឱផែនការណ៍នៃការរំដោះដ៏ធំអស្ចារ្យ
នោះរុងរឿងពេញសព្វគ្រប់ហើយណា
មានទាំងយុត្តិធម៌ស្រលាញ់ និងក្ដីមេត្តា
ក្នុងភាពដ៏សុខសាន្តអស្ចារ្យ!» 21

ខ្ញុំសូមថ្លែងជាសាក្សីក្នុងនាមជាសាវក ថាព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយគឺជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោកនេះ។ ទ្រង់បានផ្ដល់ផ្លូវទៅរកសុភមង្គលពិត។ ខ្ញុំសូមថ្លែងទីបន្ទាល់ទាំងនេះនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ


1. Talmage, James E., Jesus the Christ, Deseret Book Company (Classics in Mormon Literature Edition) ឆ្នាំ 1982 ទំព័រ 551។
2. លូកា 22:19។
3. យ៉ូហាន 13:34-35។
4. Talmage, James E., Jesus the Christ, Deseret Book Company (Classics in Mormon Literature Edition) ឆ្នាំ 1982 ទំព័រ 559 សូមមើលផងដែរ យ៉ូហាន 14:26។
5. Talmage ទំព័រ 569។
6. នីហ្វៃទី 2 9។
7. Teachings of Presidents of the Church: Joseph Smith (វគ្គសិក្សា បព្វជិតភាព និង សមាគមសង្គ្រោះ ឆ្នាំ 2007 ) ទំព័រ 49។ សូមមើលផងដែរ គ. និង ស. 20:22-25។
8. Farrar, F. W., The Life of Lives---Further Studies in the Life of Christ, Toronto William Biggs ឆ្នាំ 1900 ទំព័រ 209។
9. Gordon B. Hinckley «This Glorious Easter Morn» Ensign ខែ ឧសភា ឆ្នាំ 1996 ទំព័រ 65 និង Gordon B. Hinckley «The Symbol of Our Faith» Ensign ខែ មេសា ឆ្នាំ 2005 ទំព័រ 2--6។
10. នីហ្វៃទី 3 18:1--11។
11. ម៉ូសាយ 3:19។
12. ម៉ូសាយ 18:8--10 និង គ. និង ស. 20:37 គ. និង ស. 20:77--79។
13. ម៉ាថាយ 5:44។
14. គ. និង ស. 132:7។
15. គ. និង ស. 76:51--60,អេភេសូ 1:13--14, រ៉ូម 8:16--17។
16. គ. និង ស. 50:24។
17. ម៉ាថាយ 26:39។

18. ម៉ាថាយ 24:7 សូមមើលផងដែរ Joseph Smith translation Matthew 1:29។

19. គ. និង ស. 88:90។

20. គ. និង ស. 110។

21. «How Great the Wisdom and the Love» ដោយ Eliza R. Snow ឆ្នាំ 1804—1887 នៅក្នុង Hymns of the Church of Jesus Christ of Latter-day Saints ទំព័រ 195។